# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៨ សសរ

## សេចក្តីសំរេច

ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះត្រួតពិនិត្យ និងសិក្សាពីបញ្ហាវិវាទដីធ្លី នៅឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះត្រួតពិនិត្យ និងសិក្សាពីបញ្ហាវិវាទដីធ្លី នៅឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- ឯកឧត្តម **សេង លឹមនៅ** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ជាប្រធាន |
| ២- ឯកឧត្តម **ឡាយ សុខា** | អភិបាលខេត្តតាកែវ | ជាសមាជិក |
| ៣- ឯកឧត្តមឧត្តមសេនីយ៍ឯក **ជា តារា** | តំណាងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ | ជាសមាជិក |
| ៤- ឯកឧត្តម **អ៊ុក សុខុន** | អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ | ជាសមាជិក |

៥- ឯកឧត្តមឧត្តមសេនីយ៍ឯក **កែម សាមួន** មេបញ្ជាការយោធភូមិភាគទី៣ ជាសមាជិក

៦- ឯកឧត្តម **ហូ ទិចិត្រ** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៧- ឯកឧត្តម **ហង្ស សាមឿន** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៨- លោក **ទី សុគន្ធ** ប្រធានរដ្ឋបាលព្រៃឈើ ជាសមាជិក

៩- លោកអភិបាលស្រុកទ្រាំង ខេត្តតាកែវ ជាសមាជិក

**ប្រការ ២ :** គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ចដូចតទៅ ÷

- ចុះត្រួតពិនិត្យ និងសិក្សាដល់មូលដ្ឋានដែលមានវិវាទ នៅទីតាំងផ្ទៃដីដាំកូនឈើរបស់ ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ជាមួយដីរបស់ប្រជាពលរដ្ឋចំនួន ៤១៤គ្រួសារ ក្នុងឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ ហើយដែលមានយោធភូមិភាគទី៣ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទជាអ្នកអនុវត្តការដាំកូនឈើ
- ធ្វើរបាយការណ៍ វាយតំលៃ សន្និដ្ឋាន និងលើកសំណូមពរ អំពីលទ្ធផល នៃការចុះត្រួតពិនិត្យ និងសិក្សា តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសុំយោបល់សំរេចពីប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** សមាជិកក្រុមការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ មេបញ្ជាការយោធភូមិភាគទី៣ អភិបាលខេត្តតាកែវ និងសាមីជនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ